# Living the Lotus 12

2023

VOL. 219

*Buddhism in Everyday Life*




**Living the Lotus**
**Vol. 219 (November 2023)**

Senior Editor: Keiichi Akagawa
Editor: Sachi Mikawa
Copy Editor: Penn Setharin
*Living the Lotus* is published monthly by Rissho Kosei-kai International, Fumon Media Center, 2-7-1 Wada, Suginami-ku, Tokyo 166-8537, Japan.
TEL: +81-3-5341-1124
FAX: +81-3-5341-1224
Email: living.the.lotus.rk-international@kosei-kai.or.jp

រីហ្សូកូសេកៃគឺជាអង្គការចលនាពុទ្ធសាសនាសកលមួយដែលមានពុទ្ធបរិស័ទ ជាច្រើន មានជំនឿលើគម្ពីរព្រះសូត្រផ្កាឈូកសដែលជាព្រះសូត្ររបស់ព្រះពុទ្ធសាសនាមួយដ៏សំខាន់។ ពុទ្ធបរិស័ទទាំងនោះ បានខិតខំអនុវត្តការបង្រៀន របស់ព្រះបរមគ្រូនៃយើងទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃដូចជា នៅកន្លែងការ ងារឬនៅក្នុងក្រុមគ្រួសាររបស់ពួកគាត់ជាដើម។ជាពិសេសគឺខំប្រឹងអនុវត្តធ្វើយ៉ាងណាអោយពិភពលោកទទួលបានសុខសន្តិភាព។

អង្គការរីហ្សូកូសេកៃ ត្រូវបានបង្កើតឡើងនៅឆ្នាំ 1983 ដោយ ស្ថាបនិក Nikkyo Niwano (1906-1999) និង, សហស្ថាបនាយិកា Myoko Naganuma (1889-1957) បច្ចុប្បន្នក្រោមការណែនាំពីលោកប្រធាន Nichiko Niwano សមាជិករីហ្សូកូ សេកៃទាំងអស់ក្នុងនាមជាពុទ្ធបរិស័ទបានកំពុងប្រឹងប្រែងយ៉ាងសកម្មក្នុងការចែករំលែកព្រះធម៌និងចូលរួមសកម្មភាពសន្តិភាពទាំងក្នុងនិងក្រៅប្រទេសក្នុងកិច្ចសហការជាមួយមនុស្សគ្រប់មជ្ឈដ្ឋាន។

The title of this newsletter, *Living the Lotus—Buddhism in Everyday Life*, conveys our hope of striving to practice the teachings of the Lotus Sutra in daily life in an imperfect world to enrich and make our lives more worthwhile, like beautiful lotus flowers blooming in a muddy pond. This newsletter aims to help people around the world apply Buddhism more easily in their daily lives.

# មានសុខភាពល្អជានិច្ចជាកាល
# ---ជំងឺក្តីទុក្ខក្តីគឺជាចំណេះដឹងល្អប្រសើរ

ព្រះគ្រូនីវ៉ាណុ នីជិកុ
ព្រះប្រធានរីហ្សុក្កូសេកៃ



## "ពេលជួបគ្រោះមហន្តរាយ... ល្អហើយដែលបានជួប"

ថ្ងៃទី ៨ ខែធ្នូគឺជាថ្ងៃបុណ្យ "ជោដូអិ" ( Jodo-e ) ដែលគេប្រារព្ធឡើងដើម្បីរំលឹកថ្ងៃដែលព្រះសម្មាសម្ពុទ្ធសក្យមុនីគោត្តមលោកបានត្រាស់ដឹងព្រមទាំងដើម្បីបង្ហាញនូវសេចក្តីដឹងគុណដោយស្មោះចំពោះព្រះអង្គ។ ខ្ញុំព្រះករុណាអាត្មាភាពសូមឱ្យអ្នកទាំងអស់គ្នា ទទួលយកពីជម្រៅនៃបេះដូងជាមួយគ្នា ថាតើយើងពិតជាអស្ចារ្យ និងត្រូវដឹងគុណប៉ុណ្ណា ដែលបានជួបនឹងព្រះធម៌ជាការប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ។

ដូចគ្នានឹងនេះដែរ ថាដូចគ្នាក៏ថាបាន គឺនៅថ្ងៃបុណ្យជោដូអេ ( Jodo-e ) នាឆ្នាំ1828 ព្រះសង្ឃដ៏ឧត្តម ព្រះនាមរ្យោកាំង ( Master Ryokan ) នៃគណៈហ្សេង ( Zen ) បានផ្ញើសច្ចធម៌ជា "ព្រះធម៌រស់រវើកហាក់ដូចជាមានសរសៃឈាមដែលមានឈាមកំពុងតែរត់ "ដែលព្រះសម្មាសម្ពុទ្ធទ្រង់បានត្រាស់ដឹងក្នុងបែបបទជាសារទៅកាន់មិត្តម្នាក់ដែលរងគ្រោះដោយសារការរញ្ជួយដីដ៏ធំមួយ។

ព្រះគ្រូរ្យោកាំងបានសរសេរជាពាក្យកាព្យថា "ពិតជាគួរឱ្យសោកសង្រេងពន់ពេក,មនុស្សម្នាក់ដែលគេមិននឹកស្មានថាអាចនៅរស់រានមានជីវិតទៅជាបានរស់ហើយឃើញភាពដ៏សោកសៅបែបនេះ ។ ឃ្លាដំបូងព្រះអង្គសរសេរដើម្បីលួងលោមមិត្តហើ យឃ្លាបន្ទាប់គឺជាសេចក្តីជាស់តឿនមិត្តរបស់ព្រះអង្គ៖

"ពេលជួបគ្រោះមហន្តរាយ....... ល្អហើយដែលបានជួប។ពេលស្លាប់.......ល្អហើយដែលស្លាប់។"នេះជាល្បិចវេទមន្ត ដើម្បីគេចចេញពី ( ទុក្ខដែលបង្កដោយ ) គ្រោះមហន្តរាយ។ក្នុងលោកនេះ គ្មាននរណាម្នាក់អាចជៀសផុតពីគ្រោះមហន្តរាយ និងការរងទុក្ខដោយសារ កំណើត ជរា ជំងឺ និងមរណៈបានឡើយ។ អ្វីដែលកម្លាំងមនុស្សមិនអាចជួយបានគឺមានតែទទួលយកវាដោយបានបទតែប៉ុណ្ណោះ។នេះជាមធ្យោបាយតែមួយគត់ដើម្បីជៀសវាងកុំឱ្យទុក្ខវេទនាវាកិនយើងឱ្យសំប៉ែតរាបក្បាលដល់ដី ។

"ពេលជួបគ្រោះមហន្តរាយ..... ល្អហើយដែលបានជួប"។ មើលមួយខ្ទាច់ដំបូង វាអាចហាក់បីដូចជាពាក្យសម្ដីដ៏គ្រោតគ្រាតគ្មានភាពកក់ក្ដៅបន្តិច ក៏ប៉ុន្តែនៅរាល់ពេលដែលខ្ញុំព្រះករុណាអាត្មាភាពឃើញឃ្លានេះ ឬក៏និយាយពាក្យនេះ ខ្ញុំព្រះករុណាអាត្មាភាពមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងដោយអារម្មណ៍របស់ខ្ញុំព្រះករុណាអាត្មាភាពឡើងស្រស់បស់ ។ គឺស្រស់បស់ដោយបានឮការនិយាយពាក្យពិតពោរពេញទៅដោយសេចក្ដីមេត្តា តែដែលធម្មតាពិបាកនឹងនិយាយចេញមកក្រៅបានហើយនឹងឃើញទំនាក់ទំនងដែលពោរពេញទៅដោយការជឿទុកចិត្តគ្នារវាងខ្លួននឹងមិត្តរបស់ខ្លួន (ជាព្រះសង្ឃ) ដែលមានសារធាតុរឹងមាំអាចទទួលយកវា។

ការរស់នៅប្រកបដោយសុខភាពល្អ និងដោយភាពសុខសាន្ត គឺការរស់នៅរាល់ថ្ងៃដោយដឹងគុណនិងមានអារម្មណ៍បែបនេះ។

## មានតែ "ការភ្ញួររាស់ស្រែបេះដូង"តែប៉ុណ្ណោះទេ

នៅក្នុងគម្ពីរព្រះបទុមសូត្រមានពាក្យមួយឃ្លាថែងថា "ទេវទត្តគឺជាចំណេះដឹងល្អប្រសើរ" ។ ទេវទត្តជាបុគ្គលដែលព្យាយាមធ្វើគតព្រះសម្មា សម្ពុទ្ធសក្យមុនីគោត្តម ទោះបីជាខ្លួនជាសាវ័កនិងជាប់ជាសាច់សាលោហិតជាមួយនឹងព្រះអង្គក្ដី។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ហៅបុគ្គលនេះថាជាអ្នកមានចំណេះដឹងល្អប្រសើរ។បើតាមការបកស្រាយរបស់ព្រះស្ថាបនិកកៃសូសាម៉ាគឺជា "មិត្តដែលបំបើកភ្នែករបស់យើងឱ្យភ្លឺចំពោះសំណួរដ៏ធំថាតើយើងគួររស់នៅដោយរបៀបណា" ។ លើសពីនេះទៀតព្រះគ្រូអេយកាំងរីស្ស៊ី (Eikan Risshi) នៃវត្តហ្សែនរីង (Zenrin ji) នៅទីក្រុងក្យូតូបានមានពុទ្ធដីកាថា "ជំងឺគឺជាចំណេះដឹងល្អដ៏ពិត" នៅទីនេះយើងអាចឃើញអារម្មណ៍នៃការដឹងគុណរបស់លោកនៅក្នុងពុទ្ធដីកាថា "អ្វីដែលបានសង្គ្រោះខ្ញុំព្រះករុណាអាត្មាភាពដែលមានសុខភាពខ្សោយនោះគឺជំងឺខ្លួនវាផ្ទាល់នោះឯង។វានាំឱ្យខ្ញុំព្រះករុណាអាត្មាភាពចាប់ភ្លឹកពីសច្ចធម៌" ។

ពេលជួបគ្រោះមហន្តរាយ ឬជំងឺ វាជារឿងធម្មតាទេដែលយើងត្អូញត្អែរនោះ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើយើងទទួលយកបានថាគ្រោះមហន្តរាយ ឬជំងឺគឺជាច្បាប់សាកល ហើយចាត់ទុកពួកគេថាជាចំណេះដឹងដ៏ល្អប្រសើរ ជំនួសឱ្យការត្រូវបានគ្របដណ្ដប់ដោយភាពទុក្ខសោក យើងនឹងដាស់ស្មារតីយើងឱ្យដើរឆ្ពោះទៅមុខដោយស្ងប់ស្ងាត់ និងរឹងមាំ។

នៅក្នុងទស្សនាវដ្ដីប្រចាំខែមករានេះ ខ្ញុំព្រះករុណាអាត្មាភាពបាននិយាយអំពីសារធាតុនៃមនុស្សគឺថាយើងជាអត្ថិភាពដែលមានសុខភាពល្អ។បើយើងគិតដូច្នេះហើយមើល យើងនឹងឃើ ញថាយើងត្រូវបានផ្ដល់ដោយធម្មជាតិ នូវរាងកាយដែលមានសុខភាពល្អ និងថាមពល ហើ យសូម្បីតែមានពេលខ្លះយើងមិនស្វស្រួលខ្លួនក្ដី ក៏យើងត្រូវបានផ្ដល់មកឱ្យនូវសមត្ថភាពសម្រាប់បំប្លែងវាទៅជាកម្លាំងដើម្បីរស់ដែរ។

ដើម្បីចំណាយពេលចូលឆ្នាំថ្មីឱ្យកាន់តែមានសេចក្ដីសុខសេចក្ដីសប្បាយ ខ្ញុំព្រះករុណាអាត្មាភាពចង់តែទៅសួរសុខទុក្ខព្រះសម្មាសម្ពុទ្ធសក្យមុនីគោត្តមដោយចិត្តស្រស់ស្រាយ ហើយគិតអំពីការភ្ជួររាស់និងដាំដុះថ្នាលស្រែចិត្ត ព្រមទាំងគិតដល់ការងារសរសេររបស់ខ្ញុំព្រះករុណាអាត្មាភាពផងដែរ។

『ទស្សនាវត្តីកូសេ』 លេខខែធ្នូឆ្នាំ២០២៣



# Rissho Kosei-kai International

**Make Every Encounter Matter**



## A Global Buddhist Movement




**Information about local Dharma centers**

**facebook**

**twitter**

We welcome comments on our newsletter Living the Lotus: living.the.lotus.rk-international@kosei-kai.or.jp